# សូចនាករតាមដានរួមគ្នាសម្រាប់វេទិកាកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជាលើកទី២ ថ្ងៃទី៤-៥ ខែធ្នូ ឆ្នាំ២០០៨
## អនុវត្ត និងតាមដានរួមគ្នាសម្រាប់រយៈពេលចាប់ពីវេទិកាលើកទី២ ដល់វេទិកាលើកទី៣

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| **ការអនុវត្តន៍ និងគ្រប់គ្រងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១- អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការដោយសម្របសម្រួលការគាំទ្រ | ១- ក្រសួងផែនការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០០៩ សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ ។ ដៃគូអភិវឌ្ឍន៍ផ្តល់ឱ្យក្រសួងផែនការនូវបញ្ជីគម្រោងទាំងអស់ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ (រួមទាំងបញ្ជីគម្រោងគាំទ្រក្រសួងផែនការ) និងរបាយការណ៍វាយតម្លៃសមត្ថភាពខាងស្ថាប័ន ការខ្វះប្រហោង និងតម្រូវការសម្រាប់ក្រសួងផែនការ ។<br>២- ដៃគូអភិវឌ្ឍន៍ផ្តល់ការគាំទ្រប្រកបដោយការសម្របសម្រួលប្រសើរជាងមុន សម្រាប់អនុវត្តផែនការយុទ្ធសាស្ត្រក្រសួងផែនការ | ក្រសួងផែនការ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីផែនការ និងកាត់បន្ថយភាពក្រីក្រ | ផែនការយុទ្ធសាស្ត្ររបស់ក្រសួងផែនការ | ថវិការដ្ឋ និងដៃគូអភិវឌ្ឍន៍ |
| ២- អនុវត្ត និងត្រួតពិនិត្យការអនុវត្តន៍អាទិភាពស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការតាមអភិក្រមភាពជាដៃគូ ដើម្បីសម្រេចគោលដៅផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ១- សម្រាប់រាជរដ្ឋាភិបាល ពិគ្រោះយោបល់ផ្ទៃក្នុង និងនៅកម្រិតខ្ពស់ ដើម្បីកំណត់នូវសកម្មភាពមួយចំនួនដែលមានលក្ខណៈជាក់ស្តែង អាចសម្រេចបាន និងអាចតាមដានបាន សម្រាប់អនុវត្តនៅថ្នាក់ជាតិ និងនៅតាមវិស័យពាក់ព័ន្ធ ដើម្បីពន្លឿនវឌ្ឍនភាពនៃការអនុវត្តន៍អាទិភាពនិងការប្តេជ្ញាជម្រុញប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ<br>២- សម្រាប់ដៃគូអភិវឌ្ឍន៍ ពិគ្រោះយោបល់ជាអន្តរជាតិ និងជាមួយទីស្នាក់ការកណ្តាល (ឈរលើមូលដ្ឋាននៃវេទិកាកម្រិតខ្ពស់ស្តីពីប្រសិទ្ធភាពហិរញ្ញប្បទានសហប្រតិបត្តិការ) និងជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីឯកភាពនូវសកម្មភាពមួយចំនួនដែលមានលក្ខណៈជាក់ស្តែង អាចសម្រេចបាន និងអាចតាមដានបាន សម្រាប់ជម្រុញការអនុវត្តន៍អាទិភាព និងការប្តេជ្ញាស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ<br>៣- សម្រាប់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ឯកភាពនាត្រីមាសទី១ ឆ្នាំ២០០៩ នូវសកម្មភាព | ក.អ.ក/គ.ជ.នា | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីភាពជាដៃគូ និងសុខដុមនីយកម្ម | | កម្មវិធីគាំទ្រពហុដៃគូអភិវឌ្ឍន៍ |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | អនុវត្តរួមគ្នាមួយចំនួន ដែលជាក់ស្តែង និងអាចតាមដានបាន ផ្អែកលើផែនការសកម្មភាពស្តីពីសុខដុមនីយកម្ម ការតម្រឹម និងលទ្ធផល | | | | |
| **អាទិភាពក្នុងវិស័យសង្គមកិច្ចនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ** | | | | | |
| ៣- បង្កើនអត្រាឡើងថ្នាក់របស់សិស្សនៅកម្រិតបឋមសិក្សា ពី ៧៨,៦% ក្នុងឆ្នាំសិក្សា ២០០៦-០៧ ដល់ ៨៤% ក្នុងឆ្នាំសិក្សា ២០០៨-០៩ | ១- កាត់បន្ថយចំនួនសាលារៀនមិនគ្រប់កម្រិតពី២១% នៅឆ្នាំសិក្សា២០០៧-០៨ មកត្រឹម១៨% នៅឆ្នាំសិក្សា២០០៨-២០០៩ និងចាត់បញ្ជូនគ្រូដែលទើបចេញពីសាលាគរុកោសល្យចំនួន ៩៥% ទៅសាលារៀនដែលខ្វះគ្រូ និងនៅតំបន់ដាច់ស្រយាល<br>២- កែសម្រួលឡើងវិញនូវបទបញ្ញត្តិពាក់ព័ន្ធនឹងការឡើងថ្នាក់របស់សិស្ស និងអនុវត្តបទបញ្ញត្តិទាំងនេះនៅក្នុងកម្មវិធីវិស័យអប់រំ ដែលគាំទ្រដោយដៃគូអភិវឌ្ឍន៍ | ក្រសួងអប់រំ យុវជន និងកីឡា | ក្រុមការងារបច្ចេកទេសចម្រុះវិស័យអប់រំ | | |
| ៤- បង្កើនចំនួនស្រ្តីសម្រាលបុត្រដោយឆ្មបជំនាញឱ្យបាន៥០% នៅខែធ្នូ ឆ្នាំ២០០៩ | ១- ជ្រើសរើសឆ្មបយ៉ាងតិច៧៩នាក់ សម្រាប់មណ្ឌលសុខភាព៧៩ ដែលបច្ចុប្បន្ននៅមិនទាន់មានឆ្មប ឱ្យបាននៅដំណាច់ឆ្នាំ២០០៩<br>២- ផ្តល់ប្រាក់ឧបត្ថម្ភដល់ឆ្មប រួមទាំងមារអនុមតិកាំប្រាក់បៀវត្សរ៍របស់ឆ្មប និងប្រាក់ឧបត្ថម្ភសម្រាប់ហានិភ័យក្នុងវិជ្ជាជីវៈ ដែលបានរៀបចំដោយក្រសួងសុខាភិបាលសម្រាប់ស្នើជូនគណៈរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច ។<br>៣- ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍បង្កើនធនធានដល់គម្រោង RMNCH ក្នុងឆ្នាំ ២០០៩ និងរំលេចធនធានទាំងនេះក្នុងផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំនៅគ្រប់កម្រិត | ក្រសួងសុខាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះសុខាភិបាល | | |
| ៥- ពង្រឹងការឆ្លើយតបទៅនឹងការរាលដាលនៃជំងឺអេដស៍ | បង្កើនភាគរយនៃស្រ្តីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍បានទទួលឱសថប្រឆាំងមេរោគអេដស៍ ពី៣០% ដល់ ៤០% ត្រឹមឆ្នាំ២០០៩ ដើម្បីកាត់បន្ថយការចម្លងពីម្តាយទៅកូន | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីការងារអេដស៍ | ធនធាន គ្រប់គ្រាន់ | |
| ៦- បង្កើតអភិក្រមសមស្រប និងរួមគ្នាមួយដើម្បីកាត់បន្ថយផលប៉ះពាល់នៃការកើនឡើងតម្លៃស្បៀងទៅលើសន្តិសុខស្បៀងតាមគ្រួសារ និងសកម្មភាពអាទិភាពមួយ | បង្កើតប្រព័ន្ធត្រួតពិនិត្យរួមដើម្បីតាមដានផលប៉ះពាល់នៃការកើនឡើងនូវតម្លៃស្បៀងទៅលើសន្តិសុខស្បៀងនៅតាមគ្រួសារ | ក្រុមប្រឹក្សាស្តារ និងអភិវឌ្ឍន៍កសិកម្ម និងជនបទ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីសន្តិសុខស្បៀង និងអាហារូបត្ថម្ភ | US$25,000 | ADB, WFP, FAO, UNICEF, WHO, EU |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| ចំនួនត្រូវអនុវត្ត និងធ្វើបច្ចុប្បន្នភាពយ៉ាងទៀងទាត់ | | | | | |
| **អាទិភាពក្នុងវិស័យសេដ្ឋកិច្ចនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ៧- អនុវត្តយុទ្ធសាស្ត្រកសិកម្ម និងទឹក | ១- រៀបចំបញ្ចប់កម្មវិធីជាតិទី២ ទី៣ និងទី៤ ត្រឹមខែធ្នូ ឆ្នាំ២០០៨<br>២- រៀបចំបញ្ចប់កម្មវិធីជាតិទី១ និងទី៥ ត្រឹមខែមិថុនា ឆ្នាំ២០០៩<br>៣- រៀបចំយន្តការដើម្បីអនុវត្ត (រួមទាំងយន្តការគ្រប់គ្រង និងផ្តល់ហិរញ្ញប្បទាន) និងអនុវត្តចាប់ពីខែមិថុនា ឆ្នាំ២០០៩<br>៤- យុទ្ធសាស្ត្រវិស័យកសិកម្ម និងទឹកផ្តល់ក្របខ័ណ្ឌសកម្មភាពសម្រាប់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍<br>៥- បន្តលើកកំពស់ការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ : ដៃគូទាំងអស់ទទួលបានព័ត៌មានស្តីពីសកម្មភាពរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នៅក្នុងវិស័យកសិកម្ម និងទឹក ដោយធ្វើបច្ចុប្បន្នភាពទិន្នន័យនៅលើគេហទំព័ររបស់ក្រុមការងារចម្រុះស្តីពីកសិកម្ម និងទឹក | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងធនធានទឹក និងឧតុនិយម | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកសិកម្ម និងទឹក | | |
| ៨- អនុវត្តបទដ្ឋានគតិយុត្តិទាំងឡាយនៃច្បាប់ភូមិបាល | ១- ដីសហគមន៍ជនជាតិដើមភាគតិច<br>ក- អនុម័តអនុក្រឹត្យស្តីពីនីតិវិធីនៃការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច នៅក្នុងឆ្នាំ២០០៨ ដោយរួមទាំងការរៀបចំផែនការហិរញ្ញវត្ថុ និងមន្ត្រី ដើម្បីពន្លឿនការអនុវត្តន៍ការចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិច<br>ខ- វាយតម្លៃវិធានការបណ្តោះអាសន្នសម្រាប់ការពារដីសហគមន៍ជនជាតិភាគតិច<br>២- ការកាន់កាប់ដីរបស់ប្រជាជនក្រីក្រនៅទីប្រជុំជន : រៀបចំសេចក្តីព្រាងគោលនយោបាយស្តីពីលំនៅដ្ឋាន ដែលរួមបញ្ចូលសុវត្ថិភាពនៃការកាន់កាប់ដីធ្លីសម្រាប់អ្នកក្រីក្រនៅទីប្រជុំជន ដើម្បីជាធាតុចូលក្នុងការរៀបចំ «ឯកសារស» សម្រាប់វិស័យដីធ្លី | ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រសួងមហាផ្ទៃ<br><br>ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ក្រសួងរៀបចំដែនដី | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីដីធ្លី | | គម្រោងសាកល្បងរបស់ GTZ/DANIDA/DFID/NZAID<br><br>ដៃគូអភិវឌ្ឍន៍កំពុងពិនិត្យអំពីការអនុវត្តន៍ |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ<br>ធនធាន | <br>ប្រភព |
|---|---|---|---|---|---|
| | | នគរូបនីយកម្ម សំណង់<br>សាលាក្រុង | | | LA-SSP<br>DPs |
| | ៣- ការរៀបចំដែនដី ៖ រៀបចំសេចក្តីព្រាង *Spatial Planning Policy* ដែលចែងពីថានានុក្រម នៃការប្រើប្រាស់ដីធ្លី សម្រាប់ជាធាតុចូលរៀបចំ «ឯកសារស» និងក្របខ័ណ្ឌគតិយុត្តិដើម្បីគាំទ្រដល់ការអនុវត្តន៍ | ក្រសួងរៀបចំដែនដី<br>នគរូបនីយកម្ម សំណង់<br>ក្រុមប្រឹក្សាគោល<br>នយោបាយដីធ្លី | | | LA-SSP<br>DPs |
| ៩- ដើម្បីបញ្ឈប់ការបាត់បង់ធនធានព្រៃឈើ ដែលឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា និងយុទ្ធសាស្ត្រចតុកោណ និងដើម្បីគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រ និងបំរែបំរួលអាកាសធាតុ ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនក្របខ័ណ្ឌគតិយុត្តិ ដែលមានចែងក្នុងច្បាប់ព្រៃឈើ ច្បាប់ស្តីពីតំបន់ការពារធម្មជាតិ ច្បាប់ភូមិបាល ច្បាប់រ៉ែ និងពិសេសអនុក្រឹត្យស្តីពីដីសម្បទានសេដ្ឋកិច្ច នៅគ្រប់កម្រិត ព្រមទាំងផ្តល់រៀបចំបញ្ចប់កម្មវិធីព្រៃឈើជាតិ និងការអភិវឌ្ឍន៍សហគមន៍ | ១- អនុវត្តបណ្តាច្បាប់ និងបទបញ្ញត្តិដែលមានជាធរមាន ដោយត្រូវរៀបចំសៀវភៅចុះបញ្ជី និងផ្សព្វផ្សាយសាធារណៈអំពីដីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ និងសម្បទានផ្សេងៗទៀត ដែលស្ថិតក្រោមសមត្ថកិច្ចក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងក្រសួងបរិស្ថាន | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល<br>ក្រសួងបរិស្ថាន | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីព្រៃឈើ និងបរិស្ថាន | | |
| | ២- បោះព្រំប្រទល់ដែនព្រៃឈើឱ្យបានយ៉ាងតិច១.០០០គ.ម និងកំណត់ព្រំប្រទល់តំបន់ការពារធម្មជាតិឱ្យបានយ៉ាងតិច ២តំបន់ ទាំងនៅលើផែនទី ទាំងនៅមូលដ្ឋាន | រដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងបរិស្ថាន | | | DANIDA/<br>DFID/NZAID<br>and others |
| | ៣- អនុមតិសហគមន៍ព្រៃឈើ១០០ និងតំបន់ការពារសហគមន៍១០ យ៉ាងតិចថែមទៀត | រដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>ក្រសួងបរិស្ថាន | | | DANIDA/<br>DFID/NZAID<br>and others |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | ៤- រៀបចំបញ្ចប់កម្មវិធីព្រៃឈើជាតិ ខែកញ្ញា ឆ្នាំ២០០៩ និងអនុវត្តនៅដំណាច់ឆ្នាំ២០០៩ | រដ្ឋបាលព្រៃឈើ<br>ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | | DANIDA/<br>DFID/NZAID<br>and others |
| ១០- ចាត់វិធានការសមស្របដើម្បីរំលេចអាទិភាពវិស័យជលផល ទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ស្រុក ខេត្ត ដោយបញ្ជាក់ពីកម្រិតនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ | ១- យ៉ាងហោចណាស់ ៨០%នៃផែនការប្រចាំឆ្នាំរបស់រដ្ឋបាលជលផល ត្រូវបានគាំទ្រដោយដៃគូអភិវឌ្ឍន៍ តាមរយៈកម្មវិធីគ្រប់គ្រងទូទាំងវិស័យ នាដំណាច់ឆ្នាំ២០០៩<br>២- ក្រមប្រតិបត្តិការធ្វើនេសាទប្រកបដោយការទទួលខុសត្រូវនៅកម្ពុជាត្រូវអនុម័ត និងអនុវត្តចាប់ពីដំណាច់ឆ្នាំ២០០៩ | រដ្ឋបាលជលផល | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីជលផល | | Danida/Dfid<br>/NZAid/JICA<br>/Worldfish<br>Center and<br>others |
| ១១- កាត់បន្ថយគ្រោះថ្នាក់ដោយសារមីនចំនួន៥០ករណី និងកាត់បន្ថយពី៧-១០% នៃផ្ទៃដីដែលមានមីន | ១- ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តន៍គោលនយោបាយសកម្មភាពមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ព្រមទាំងរៀបចំយុទ្ធសាស្រ្តជាតិស្តីពីការបោសសំអាតមីនសម្រាប់រយៈពេល ១០ឆ្នាំ<br>២- អនុវត្តផែនការយុទ្ធសាស្រ្ត ២០០៩-២០១១ ដើម្បីកាត់បន្ថយការបែកខ្ញែក និងការត្រួតគ្នា<br>៣- កែលំអគុណភាពទិន្នន័យស្តីពីការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ដើម្បីលើកកំពស់ផែនការនីយកម្មរបស់វិស័យនេះ | អាជ្ញាធរមីន | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីមីន | $2.9 M.<br>$22 M. | រាជរដ្ឋាភិបាល<br>ដៃគូអភិវឌ្ឍន៍ |
| ១២- បង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន | ១- បង្កើនវឌ្ឍនភាពក្នុងក្របខ័ណ្ឌគតិយុត្តិ ដើម្បីបង្កើតបរិយាកាសអំណោយផលដល់ការអភិវឌ្ឍន៍របស់វិស័យឯកជន (របៀបវារៈនឹងត្រូវឯកភាពតាមរយៈក្រុមការងារច្បាប់ពន្ធដារ និងអភិបាលកិច្ច)<br><br>២- អនុមតិផែនការរំកិលបីឆ្នាំសម្រាប់កំណែទម្រង់ពាណិជ្ជកម្ម (កម្មវិធីគ្រប់គ្រងទូទាំងវិស័យ) ដោយមានផែនការសកម្មភាពលំអិតតាមស្ថាប័ន ក្របខ័ណ្ឌតាមដានរឹងមាំ និងសុខដុមនីយកម្មនៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ | ក.អ.ក ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>ក្រសួងពាណិជ្ជកម្ម<br><br>ក្រសួងពាណិជ្ជកម្ម<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង | ក្រុមការងារស្តីពីការអភិវឌ្ឍន៍វិស័យឯកជន | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ | |
|---|---|---|---|---|---|
| | | | | ធនធាន | ប្រភព |
| | | ឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក.អ.ក និងក្រសួងសុខាភិបាល | | | |
| **អាទិភាពក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១៣- ចីរភាពនិងសុវត្ថិភាពនៃបណ្តាញផ្លូវជាតិ និងផ្លូវជនបទ | ១- វិធានការថែទាំផ្លូវ<br>- កែលំអយន្តការថែទាំផ្លូវ<br>- កែលំអកម្មវិធីគ្រប់គ្រងការដឹកជញ្ជូនលើសទម្ងន់<br>២- អនុវត្តកម្មវិធីយល់ដឹងពីសុវត្ថិភាពផ្លូវថ្នល់ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ក្រុមការងារបច្ចេកទេសស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ | US$ 0.23 M. | ហិរញ្ញប្បទាន ADB |
| ១៤- បង្កើនការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតាមជនបទ | ១- រៀបចំ និងអនុវត្តយុទ្ធសាស្ត្រស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យ ព្រមទាំងថវិកាដែលផ្អែកលើគោលនយោបាយស្តីពីការផ្គត់ផ្គង់ទឹកនៅជនបទ និងអនាម័យ ដោយត្រូវតម្រឹមជាមួយនឹងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ | ក្រសួងអភិវឌ្ឍន៍ជនបទ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីទឹកស្អាត និងអនាម័យនៅជនបទ | | ADB, UNICEF និងដៃគូអភិវឌ្ឍន៍ដទៃទៀត |
| **អាទិភាពក្នុងវិស័យអភិបាលកិច្ច និងពហុវិស័យនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** | | | | | |
| ១៥- កែលំអគុណភាពនៃការផ្តល់សេវាសាធារណៈ | ១- អនុវត្តយន្តការស្តីពីការពិនិត្យគុណភាពសេវា និងគណនេយ្យភាព ដោយបង្កើតភ្នាក់ងារប្រតិបត្តិការពិសេស កន្សោមអាទិភាព និងប្រព័ន្ធលាភការផ្អែកលើលទ្ធផលការងារ<br>២- អនុមតិគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្ស ការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សមត្ថភាព | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់រដ្ឋបាល | | |
| ១៦- រៀបចំប្រព័ន្ធច្បាប់ និងតុលាការ ឱ្យដំណើរការល្អ ប្រកបដោយគណនេយ្យភាព | ១- គោលដៅទី២នៃយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់និងតុលាការ : រៀបចំបញ្ចប់សេចក្តីព្រាងច្បាប់បួន គឺក្រមព្រហ្មទណ្ឌ ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម ច្បាប់ស្តីពីការរៀបចំ និងការ | ក្រសួងយុត្តិធម៌ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ | | ក្រសួងយុត្តិធម៌ប្រទេសបារាំង |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ<br>ធនធាន | <br>ប្រភព |
|---|---|---|---|---|---|
| និងតម្លាភាពដែលការពារសិទ្ធិបុគ្គលដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ | ប្រព្រឹត្តទៅរបស់តុលាការ ច្បាប់វិសោធនកម្មស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម<br>២- អនុវត្តក្របខ័ណ្ឌនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ដោយ :<br>ក- ការចុះបញ្ជីសំណុំរឿងនៅតាមតុលាការគំរូទាំងបួន<br>ខ- បន្តបណ្តុះបណ្តាលមន្ត្រីតុលាការ ដើម្បីបង្កើនគុណភាពសេវា និងកិច្ចដំណើរការរបស់តុលាការ | | ច្បាប់ និងប្រព័ន្ធតុលាការ | | 2a)MOJ, AusAID, Danida, UNICEF, USAID<br><br>2b)MOJ, RAJP, JICA, France |
| ១៧- បន្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ | ១- បន្ទាប់ពីការអនុមតិក្រុមព្រហ្មទណ្ឌ រៀបចំបញ្ចប់សេចក្តីព្រាងច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ ស្របតាមបទដ្ឋានអន្តរជាតិ ហើយស្នើជូនរដ្ឋសភានិងព្រឹទ្ធសភាអនុមតិ<br><br>២- រៀបចំផែនការដើម្បីអនុវត្តច្បាប់ស្តីពីការប្រឆាំងនឹងអំពើពុករលួយ<br>៣- ផ្សព្វផ្សាយរៀងរាល់៦ខែម្តង នូវព័ត៌មានស្តីពីករណីពុករលួយ និងការផ្តន្ទាទោស<br>៤- រៀបចំគោលនយោបាយស្តីពីសិទ្ធិទទួលព័ត៌មាន | ទីស្តីការគណៈរដ្ឋមន្ត្រី | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | | |
| ១៨- រៀបចំអនុវត្តឱ្យបានពេញលេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រជាតិស្តីពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ | ១- បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ស្របតាមច្បាប់អង្គការ<br>២- បញ្ចប់ការរៀបចំ និងអនុមតិកម្មវិធីជាតិនៅដំណាច់ឆ្នាំ២០០៩ | គណៈកម្មាធិការជាតិដឹកនាំកំណែទំរង់វិមជ្ឈការនិងវិសហមជ្ឈការ | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីវិមជ្ឈការនិងវិសហមជ្ឈការ | | |
| ១៩- អនុវត្តកម្មវិធីកំណែទ្រមង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២ ដើម្បីពង្រឹងគណនេយ្យភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ<br>- អនុវត្ត និងតាមដានការអនុវត្តន៍ផែនការសកម្មភាពជំហានទី២<br>- សម្រេចឱ្យបាននូវគោលដៅដែលបានឯកភាពស្របតាមផែនការសកម្មភាពជំហានទី២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមជាមួយបណ្តាក្រសួងនិងស្ថាប័ន | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ | | |
| ២០- អនុម័តច្បាប់ អនុក្រឹត្យ និងផែនការស្តីពីការប្រឆាំងអំពើហិង្សា និងអាជីវកម្មលើ | ១- កែសម្រួលអនុក្រឹត្យស្តីពីការសម្រេចចិត្តផ្នែករដ្ឋបាលស្តីពីអំពើហិង្សាក្នុងគ្រួសារ និងបង្កើតក្រុមការងារដើម្បីបណ្តុះបណ្តាល និងអនុវត្តអនុក្រឹត្យ | ក្រសួងមហាផ្ទៃ<br>ក្រសួងកិច្ចការនារី | ក្រុមការងារបច្ចេកទេសចម្រុះស្តីពីយេនឌ័រ | | |

| គោលដៅ | សកម្មភាពចាំបាច់ | ស្ថាប័នទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល | ក្រុមការងារបច្ចេកទេសចម្រុះពាក់ព័ន្ធ | តម្រូវការធនធានដើម្បីសម្រេចគោលដៅ ធនធាន | ប្រភព |
|---|---|---|---|---|---|
| ស្ត្រីនិងកុមារ ស្របតាមបទដ្ឋានអន្តរជាតិ | ២- រៀបចំក្របខ័ណ្ឌរួមមួយដើម្បីតាមដាន និងអនុវត្តច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ<br><br>៣- កែសម្រួល និងអនុមតិផែនការសកម្មភាពជាតិប្រឆាំងនឹងអំពើហិង្សាលើស្ត្រី<br><br>៤- ពិនិត្យគោលនយោបាយស្តីពីចំណាកស្រុក ។ គោលដៅជាក់លាក់រួមមាន អនុមតិយុទ្ធសាស្ត្រស្តីពីចំណាកស្រុក ដោយភ្ជាប់ជាមួយការជួញដូរ ការរត់ពន្ធ និងច្បាប់ការងារ ព្រមទាំងបំពេញចន្លោះប្រហោងខាងទិដ្ឋភាពច្បាប់ ដើម្បីការពារជនចំណាកស្រុក | ក្រសួងមហាផ្ទៃ<br>ក្រសួងកិច្ចការនារី<br><br>ក្រសួងកិច្ចការនារី<br><br>ក្រសួងមហាផ្ទៃ<br>ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>ក្រសួងយុត្តិធម៌<br>ក្រសួងកិច្ចការនារី | | | |